# មុខងារនៃអង្គនីតិបញ្ញត្តិ

## ក) គោលការណ៍ទូទៅនៃនីតិកម្មតាមបែបលទ្ធិប្រជាធិបតេយ្យ៖

ក្រុមមនុស្ស ឬ សង្គមណាមួយ ត្រូវតែដោះស្រាយនូវបញ្ហារួមរបស់ពួកគេ ។ ព្រោះហេតុដូច្នេះ គេត្រូវតែធ្វើសេចក្តីសម្រេច និងបង្កើតច្បាប់សម្រាប់សមាជិកក្រុមទាំងអស់ ហើយគេត្រូវគ្រប់គ្រងនូវការអនុវត្តន៍សេចក្តីសម្រេច និងច្បាប់ទាំងនេះ ។

គេអាចឆ្លើយនូវសំណួរអំពីរបៀបរៀបចំ ដំណើរការនៃការធ្វើសេចក្តីសម្រេច តាមវិធីផ្សេងៗ ដូចតទៅ:

នៅក្នុងក្រុមមនុស្ស ឬសង្គមខ្លះ សេចក្តីសម្រេចគ្រាន់តែធ្វើឡើងដោយ

| មនុស្សម្នាក់<br>○<br>(រាជានិយម) | ឬដោយ | មនុស្សមួយក្រុមតូច<br>ដែលមានអភ័យឯកសិទ្ធិ និងឥទ្ធិពល<br>○○○○<br>(អភិជនាធិបតេយ្យ ឬ អប្បជនាធិបតេយ្យ) |
|---|---|---|

ដែលគ្រប់គ្រង និងអនុវត្តនូវអំណាចរបស់គេ ពីលើសមាជិកដទៃទៀតនៅក្នុងសង្គម ។

ផ្ទុយអំពីនោះ ដំណើរការនៃការធ្វើសេចក្តីសម្រេច គឺជា

| កិច្ចការរួមរបស់សមាជិកទាំងអស់នៃក្រុម<br>○○○○○○○○○○○○○○<br>○○○○○○○○○○○○○○○<br>○○○○○○○○○○○○○○○○<br>(លទ្ធិប្រជាធិបតេយ្យ) |
|---|

នៅក្នុងសង្គមមួយដែលផ្អែកលើសិទ្ធិមនុស្ស ពីព្រោះ សិទ្ធិមនុស្សមូលដ្ឋានសំខាន់បំផុតគឺសិទ្ធិស្មើភាពគ្នា ។ នេះមានន័យថា រាល់មនុស្សទាំងអស់សុទ្ធតែមានតម្លៃស្មើគ្នា ទោះបីជាគេមានសញ្ជាតិ អំបូរជាតិសាសន៍ ឬចេញពីសង្គមណាមួយ ឬក៏មានជំនឿនយោបាយ ឬសាសនាអ្វីក៏ដោយ ។ នៅពេលដែលសមាជិកទាំងអស់នៃក្រុម ឬសង្គម គួរតែទទួលបាននូវការគោរពដូចៗគ្នានោះ គ្មាននរណាម្នាក់មានអភ័យឯកសិទ្ធិ ឬតម្លៃខ្ពស់ជាងដែលអាចឱ្យគេមានសិទ្ធិក្នុងការគ្រប់គ្រង និងបង្គាប់ឱ្យសមាជិកដទៃទៀតក្នុងក្រុមធ្វើអ្វីនោះឡើយ ។

ជំនួសករណីខាងលើនេះ ក្រុមនេះគ្រប់គ្រងខ្លួនដោយខ្លួនឯង ( **ស្វ័យគ្រប់គ្រង= Self-Rule** ) ។

ទាក់ទងទៅនឹងដំណើរការនៃការធ្វើសេចក្ដីសម្រេចស្វ័យគ្រប់គ្រង មានន័យថា **ពហុភាព (Pluralism) :** សម្លេងរបស់រាល់បុគ្គលដែលជាសមាជិកនៃក្រុម ឬសង្គមត្រូវតែបានគេឮ រាល់គំនិតទាំងអស់ត្រូវតែបានគេយកមកពិចារណា មនុស្សរាល់គ្នាអាចរួមចំណែកលើកឡើងនូវដំណោះស្រាយមួយសម្រាប់បញ្ហារួម ។ ប្រការនេះមានសារៈសំខាន់ ជាពិសេសសម្រាប់សមាជិកដែលស្ថិតក្នុងក្រុមភាគតិច ឬក៏មានគំនិតផ្ទុយ ។ អាស្រ័យដោយសេចក្ដីសម្រេចត្រូវតែធ្វើឡើងសម្រាប់ក្រុមទាំងមូល សេចក្ដីសម្រេចភាគច្រើនត្រូវគោរព និងពិចារណាដោយផ្អែកលើគោលជំហរសមាជិកភាគតិចផងដែរ ។

គុណវិបត្តិនៃការធ្វើសេចក្ដីសម្រេចរួមបែបនេះ អាចត្រូវចំណាយពេលច្រើនជាងការធ្វើសេចក្ដីសម្រេចដោយមនុស្សតែម្នាក់ ។ ប៉ុន្តែ គំនិតនៃការធ្វើសេចក្ដីសម្រេចរួមគឺជាការប្រកួតប្រជែង និងការពិភាក្សាទៅលើសំណើនៃដំណោះស្រាយទាំងអស់ នឹងឈានទៅរកលទ្ធផលដែលល្អ និងត្រឹមត្រូវបំផុត ពីព្រោះវារួមបញ្ចូលគ្នានូវភាពចម្រុះ កម្លាំង និងសមត្ថភាពនៃសមាជិកក្រុមទាំងអស់ ហើយវាមិនពឹងផ្អែកទៅលើសមត្ថភាពនៃអ្នកដឹកនាំតែម្នាក់នោះ ។ លើសពីនេះ ច្បាប់ និងសេចក្ដីសម្រេចនានា កាន់តែអាចទទួលយកបានសម្រាប់សមាជិកក្រុមនៅពេលដែលពួកគេមានឱកាសចូលរួមនៅក្នុងដំណើរការធ្វើសេចក្ដីសម្រេច ។ ការនេះនាំទៅរកសង្គមមួយ ដែលកាន់តែមានសន្តិភាព និងស្ថេរភាពសង្គម ។

គំរូនៃស្វ័យគ្រប់គ្រងបែបនេះ ត្រូវគេហៅថា "**លទ្ធិប្រជាធិបតេយ្យ**" ។ ពាក្យនេះ មានន័យថា "**ការគ្រប់គ្រងរបស់ប្រជាពលរដ្ឋ**" (Rule of the People) ។ វាគឺជាគំរូគ្រប់គ្រងមួយ ដែលប្រទេសកម្ពុជាបានអនុម័តយក ។

> មាត្រា៥១ I និង II នៃរដ្ឋធម្មនុញ្ញកម្ពុជា (CC)៖
>
> ព្រះរាជាណាចក្រកម្ពុជា អនុវត្តរបបនយោបាយ ប្រជាធិបតេយ្យ សេរីពហុបក្ស ។
> ប្រជាពលរដ្ឋខ្មែរ ជាម្ចាស់វាសនា នៃប្រទេសជាតិខ្លួន ។
> អំណាចទាំងអស់ជារបស់ប្រជាពលរដ្ឋ ។

គំរូបែបលទ្ធិប្រជាធិបតេយ្យ នៃការធ្វើសេចក្ដីសម្រេច និងស្វ័យគ្រប់គ្រងមិនគ្រាន់តែយកមកអនុវត្តសម្រាប់រដ្ឋសភាកម្ពុជាឡើយ គឺសម្រាប់ក្រុម និងសមាគមទាំងអស់ក្នុងសង្គមកម្ពុជា ។ ឧទាហរណ៍៖ គំរូលទ្ធិប្រជាធិបតេយ្យអនុវត្តចំពោះក្រុមប្រឹក្សាឃុំ សង្កាត់ ។

> មាត្រា៤៨ I និង II នៃច្បាប់ស្ដីអំពីការគ្រប់គ្រងរដ្ឋបាលឃុំ-សង្កាត់៖
>
> ឃុំ-សង្កាត់ មានអំណាចបញ្ញត្តិ និងប្រតិបត្តិ ។ អំណាចបញ្ញត្តិរបស់ឃុំ-សង្កាត់ ត្រូវអនុវត្តតាមរយៈដីការបស់ឃុំ-សង្កាត់ សំរាប់គ្រប់គ្រងកិច្ចការនានានៅក្នុងក្របខ័ណ្ឌ តួនាទី មុខងារ និងអំណាចរបស់ខ្លួន ។

ឬ ចំពោះគណបក្សនយោបាយ[១] សហជីពកម្មករ គណៈមេធាវី[២] អង្គការក្រៅរដ្ឋាភិបាល[៣] ឬស្ថាប័នតំណាងនិស្សិតនៅសាកលវិទ្យាល័យផ្សេងៗ ។ល។

## ២) អំណាចនីតិបញ្ញត្តិៈ ការអនុវត្តន៍អំណាចរបស់ប្រជាពលរដ្ឋ

ប្រជាពលរដ្ឋកម្ពុជា គឺជាម្ចាស់ប្រទេស និងជោគវាសនារបស់ខ្លួន ។ រាល់អំណាចនយោបាយទាំងអស់ចេញមកពីប្រជាពលរដ្ឋ ។ **អំណាចដែលសំខាន់ជាងគេ គឺអំណាចក្នុងការធ្វើសេចក្តីសម្រេច និងបង្កើតច្បាប់**នានា។ ច្បាប់ទាំងនេះចាំបាច់ត្រូវតែយកមកអនុវត្ត ។ ការអនុវត្តន៍ច្បាប់ និងសេចក្តីសម្រេចទាំងនេះ ចាំបាច់ត្រូវមានការគ្រប់គ្រង ។ ដើម្បីចៀសវាងនូវការប្រមូលផ្តុំនូវអំណាច និងការរំលោភលើអំណាចរបស់ប្រជាពលរដ្ឋ អំណាច ត្រូវតែចែកជាបីផ្នែក ( = គោលការណ៍នៃការបែងចែកអំណាច) ។

> មាត្រា៥១ III និង IV CC:
>
> អំណាចទាំងអស់ ជារបស់ប្រជាពលរដ្ឋ ។ ប្រជាពលរដ្ឋប្រើអំណាចរបស់ខ្លួនតាមរយៈ រដ្ឋសភា រាជរដ្ឋាភិបាល និងសាលាជំរះក្តី ។
> អំណាចបែងចែកដាច់ពីគ្នារវាងអំណាចនីតិបញ្ញត្តិ អំណាចនីតិប្រតិបត្តិ និងអំណាចតុលាការ ។

យោងតាមរចនាសម្ព័ន្ធនៃអំណាចនេះ **រដ្ឋសភា** (NA = អំណាចនីតិបញ្ញត្តិ) **មានតួនាទី**[៤] **សំខាន់ពីរៈ**

- **ដើម្បីធ្វើសេចក្តីសម្រេច** ( មាត្រា ៩០ I និង ៩១ I, II CC) ដែលមានន័យថា
  - តាក់តែងច្បាប់ ( មានន័យថាត្រូវបង្កើតច្បាប់ទូទៅសម្រាប់ប្រជាពលរដ្ឋកម្ពុជាទាំងអស់)
  - អនុម័តសេចក្តីសម្រេច នៃស្ថាប័ននានា ( មាត្រា ៩០ II, IV CC )
    ( ឧទាហរណ៍ៈ ធ្វើការអនុម័តថវិកាជាតិដែលដាក់ជូនដោយរដ្ឋាភិបាល ឬអនុម័តលើការលើកលែងទោសដែលផ្តល់ដោយរដ្ឋាភិបាល)
- **ដើម្បីគ្រប់គ្រងការអនុវត្តន៍សេចក្តីសម្រេច** មានន័យថា
  - ជ្រើសរើសអំណាចនីតិប្រតិបត្តិ ( =រដ្ឋាភិបាល មាត្រា១១៩ I និង II CC)
  - គ្រប់គ្រងរដ្ឋាភិបាល ដោយការចោទសួរ ចោទប្រកាន់ និង បណ្តេញពួកគេចេញ! ( មាត្រា៨៩, ៩៦ I, ៩៧, ៩៨, ១២១ និង ១២៦ CC)

---

[១] សូមមើលជាឧទាហរណ៍នូវបទបញ្ជាផ្ទៃក្នុងរបស់គណបក្សនយោបាយៈ
លក្ខន្តិកៈគណបក្សប្រជាជនកម្ពុជាៈ www.camnet.com.kh/cpp/statutes.htm
គណបក្សហ្វុនស៊ីនប៉ិចៈ www.funcinpec.org/principle.htm,

[២] មាត្រា២ និង ៣ នៃបទបញ្ជាផ្ទៃក្នុងរបស់គណៈមេធាវីៈ www.ifrance.com/cambodia/judicial/jud008g.htm

[៣] មើលមាត្រា១២ និង ១៤ នៃពង្រាងច្បាប់ស្តីពីអង្គការក្រៅរដ្ឋាភិបាល និងសមាគម

[៤] សំរាប់ព័ត៌មានលំអិតសូមមើលក្រាហ្វិកនៅទំព័រទី ២៥

មាត្រា៨៩ CC:

តាមការសុំពីសមាជិកសភាចំនួន១/១០ យ៉ាងតិច រដ្ឋសភា អាចអញ្ជើញឥស្សរជនដ៏ឧត្តមណាមួយ មកបំភ្លឺរដ្ឋសភាអំពីបញ្ហាដែលមានសារៈសំខាន់ពិសេស ។

មាត្រា៩០ CC:

រដ្ឋសភាជាអង្គការតែមួយគត់ ដែលមានអំណាចនីតិបញ្ញត្តិ ។
អំណាចនេះរដ្ឋសភា មិនអាចប្រគល់ឱ្យទៅអង្គការ ឬបុគ្គលណាមួយបានឡើយ ។
រដ្ឋសភាអនុម័តថវិកាជាតិ ផែនការរដ្ឋ ការឱ្យខ្ចីប្រាក់ពីគេ ការឱ្យរដ្ឋឱ្យប្រាក់គេខ្ចី ការសន្យានានាផ្នែកហិរញ្ញវត្ថុ និងការបង្កើត កែប្រែ ឬលុបចោលពន្ធដារ ។
រដ្ឋសភាឱ្យសេចក្តីយល់ព្រម ចំពោះគណនីរដ្ឋបាល ។
រដ្ឋសភាអនុម័តច្បាប់ ស្តីពីការលើកលែងទោសជាទូទៅ ។
រដ្ឋសភាអនុម័តយល់ព្រម ឬលុបចោលសន្ធិសញ្ញា ឬអនុសញ្ញាអន្តរជាតិ ។
រដ្ឋសភាអនុម័តច្បាប់ ស្តីពីការប្រកាសសង្គ្រាម ។

មាត្រា៩៦ CC:

តំណាងរាស្ត្រ មានសិទ្ធិដាក់សំណួរដល់រាជរដ្ឋាភិបាល ។ សំណួរនេះត្រូវសរសេរជាលាយល័ក្ខអក្សរ ប្រគល់ជូនតាមរយៈប្រធានរដ្ឋសភា ។
ចម្លើយអាចធ្វើឡើងដោយរដ្ឋមន្ត្រីមួយរូប ឬច្រើនរូប អាស្រ័យទៅតាមបញ្ហាដែលបានចោទឡើង ពាក់ព័ន្ធនឹងការទទួលខុសត្រូវរបស់រដ្ឋមន្ត្រីមួយរូប ឬច្រើនរូប ។ បើបញ្ហាពាក់ព័ន្ធដល់នយោបាយទូទៅរបស់រាជរដ្ឋាភិបាល នាយករដ្ឋមន្ត្រីត្រូវឆ្លើយផ្ទាល់ខ្លួន ។
ចម្លើយរបស់រដ្ឋមន្ត្រី ឬរបស់នាយករដ្ឋមន្ត្រី អាចធ្វើដោយផ្ទាល់មាត់ ឬសរសេរជាលាយល័ក្ខអក្សរ ។
ចម្លើយខាងលើនេះ ត្រូវធ្វើឡើងក្នុងរយៈពេលប្រាំពីរថ្ងៃបន្ទាប់ពីបានទទួលសំណួរ ។
ចំពោះចម្លើយ ផ្ទាល់មាត់ ប្រធានរដ្ឋសភាអាចសំរេចបើកឱ្យមាន ឬមិនឱ្យមានការជជែកដេញដោល ។
បើគ្មានការបើកឱ្យជជែកដេញដោលទេនោះ ចម្លើយរបស់រដ្ឋមន្ត្រី ឬនាយករដ្ឋមន្ត្រី និងបញ្ចប់សំណួរតែម្តង ។
បើមានការបើកអោយជជែកដេញដោល ម្ចាស់សំណួរ វាគ្មិនឯទៀត និងរដ្ឋមន្ត្រី ពាក់ព័ន្ធ ឬនាយករដ្ឋមន្ត្រី អាចជជែកប្តូរយោបល់ ក្នុងរយៈពេលដែលមិនអាចលើសពីមួយពេលប្រជុំឡើយ ។
រដ្ឋសភាកំណត់ទុកពេលមួយថ្ងៃ ក្នុងមួយសប្តាហ៍ សម្រាប់ការឆ្លើយសំណួរ ។
ទោះបីយ៉ាងណាក៏ដោយ សម័យប្រជុំសំរាប់ឆ្លើយសំណួរខាងលើ មិនអាចបើកលទ្ធភាពឱ្យមានការបោះឆ្នោតប្រភេទណាមួយបានឡើយ ។

មាត្រា៩៧ CC:

គណៈកម្មការទាំងឡាយរបស់រដ្ឋសភា អាចអញ្ជើញរដ្ឋមន្ត្រីមកបំភ្លឺអំពីបញ្ហាអ្វីមួយដែលពាក់ព័ន្ធនឹងវិស័យទទួលខុសត្រូវរបស់ខ្លួន ។

មាត្រា៩៨ CC:

រដ្ឋសភា អាចទម្លាក់សមាជិកគណៈរដ្ឋមន្ត្រី ឬទម្លាក់រាជរដ្ឋាភិបាលពីតំណែង ដោយអនុម័តញ្ញត្តិបន្ទោស តាមសម្លេងឆ្នោត២/៣ នៃចំនួនសមាជិករដ្ឋសភាទាំងមូល ។
ញត្តិបន្ទោសរាជរដ្ឋាភិបាល ត្រូវបានលើកឡើងជូនរដ្ឋសភា ដោយតំណាងរាស្ត្រចំនួន សាមសិបនាក់ ទើបរដ្ឋសភាអាចលើកមកពិភាក្សាបាន ។

> មាត្រា១២១ CC:
> សមាជិកទាំងឡាយនៃរាជរដ្ឋាភិបាលទទួលខុសត្រូវរួមគ្នាចំពោះរដ្ឋសភា អំពីនយោបាយទូទៅរបស់រាជរដ្ឋាភិបាល ។
> សមាជិកមួយរូបៗនៃរាជរដ្ឋាភិបាល ទទួលខុសត្រូវរៀងខ្លួន ចំពោះនាយករដ្ឋមន្ត្រី និងចំពោះរដ្ឋសភា អំពីការដែលខ្លួនបានប្រព្រឹត្ត ។

មាត្រានៃរដ្ឋធម្មនុញ្ញទាំងនេះ លើកឡើងនូវសំណួរថា **តើសិទ្ធិរបស់រដ្ឋសភាមានកម្លាំងគ្រប់គ្រាន់ ដើម្បីគ្រប់គ្រងរដ្ឋាភិបាល ឬទេ?**

បញ្ហា:

ហេតុអ្វីវាត្រូវជាឆន្ទានុសិទ្ធិរបស់បុគ្គលតែម្នាក់គឺប្រធានសភា ក្នុងការបញ្ឈប់នូវការពិភាក្សាដោយចំហអំពីញត្តិប្រឆាំងនឹងនាយយករដ្ឋមន្ត្រី ស្រេចតែចិត្តនោះ? ហេតុអ្វីបានជាវាស្រេចតែទៅលើរដ្ឋមន្ត្រី ឬ នាយក-រដ្ឋមន្ត្រី ក្នុងការជ្រើសរើស ប្រសិនបើគេចង់ឆ្លើយផ្ទាល់មាត់ ឬជាលាយល័ក្ខអក្សរនោះ? (សូមមើលមាត្រា៩៦ III, V CC) ។

## គ) ធាតុចំបងនៃការធ្វើសេចក្តីសម្រេចតាមលទ្ធិប្រជាធិបតេយ្យ[៥]:

នីតិកម្មតាមបែបលទ្ធិប្រជាធិបតេយ្យ មានន័យថា ការបង្កើតច្បាប់សម្រាប់សមាជិក**ទាំងអស់**នៃសង្គមមួយ ។ ច្បាប់មានតួនាទី ធ្វើឱ្យមានតុល្យភាពនូវសិទ្ធិមនុស្សផ្សេងៗរបស់សមាជិកនានានៃសង្គម ។ ព្រោះហេតុដូច្នេះ សមាជិកម្នាក់ៗត្រូវមានសិទ្ធិ**ចូលរួម**ក្នុងដំណើរការនៃការបង្កើតច្បាប់ ដែលអាចប៉ះពាល់ដល់កិច្ចការ និងសិទ្ធិផ្ទាល់ខ្លួនរបស់គេ ។ ដំណើរការនៃការធ្វើសេចក្តីសម្រេចជាសមូហភាពបែបនេះ ត្រូវតែធ្វើឡើងដោយ**បើកចំហ** និងប្រកបដោយ**ពហុភាព** ។ ប្រសិនបើមិនដូច្នេះទេ លទ្ធផលនៃដំណើរការនេះ នឹងមិនអាចទទួលយកបានឡើយ ជាពិសេសសម្រាប់ក្រុមមនុស្សភាគតិច និងសមាជិកប្រឆាំង ។

នីតិកម្មតាមលទ្ធិប្រជាធិបតេយ្យ មានគោលបំណងសំខាន់ពីរ:

- ដើម្បីស្វែងរក**ដំណោះស្រាយដែលប្រសើរបំផុតដែលអាចមាន**សម្រាប់បញ្ហាសង្គម **និងទំនាស់** ដែលបំពានទៅលើសិទ្ធិមនុស្សរបស់មនុស្សដែលពាក់ព័ន្ធមួយចំនួនតូច
- ដើម្បីបង្កើតនូវ**ភាពស្របច្បាប់** នៃច្បាប់

ដើម្បីសម្រេចឱ្យបាននូវគោលដៅនេះ ធាតុបីនៃដំណើរការបង្កើតច្បាប់ មានសារៈសំខាន់ណាស់ដែលមិនអាច បោះបង់ចោលបាន និងមិនធ្វើឱ្យខូចខាតចំពោះដំណើរការនីតិកម្មតាមលទ្ធិប្រជាធិបតេយ្យឡើយ ។

---

[៥] ចំពោះព័ត៌មានពិស្តារ សូមអានអត្ថបទស្តីអំពី "តួនាទីនៃអង្គនីតិបញ្ញត្តិក្នុងសង្គមប្រជាធិបតេយ្យ" http: //usinfo.state.gov/products/pubs/archive/freedom/freedom3.htm
សូមអានព័ត៌មានបន្ថែមអំពី "ការបង្កើត និងផ្សព្វផ្សាយច្បាប់ក្នុងសង្គមប្រជាធិបតេយ្យ" http: //usinfo.state.gov/products/pubs/archive/freedom/freedom7.htm
សូមអាន: Putzig/Rendall: "លទ្ធិប្រជាធិបតេយ្យ: តួនាទីរបស់ប្រជាពលរដ្ឋ" និង Rendall: "រដ្ឋធម្មនុញ្ញ និងរដ្ឋាភិបាលកម្ពុជា" ។ សៀវភៅទាំងពីរនេះ មានបោះពុម្ពជាភាសាខ្មែរ ដោយ"មជ្ឈមណ្ឌលអប់រំច្បាប់សហគមន៍" (CLEC) ផ្ទះលេខ៥៤ ផ្លូវ៣០៦-៣៥៤ ភ្នំពេញ

ធាតុទាំងបីនេះគឺ:

**ភាពជាតំណាង**
នៃរាល់សមាជិក
ក្នុងសង្គមទាំងអស់



**តម្លាភាព** និង
**ការផ្សព្វផ្សាយ** អំពី
ការធ្វើសេចក្ដីសម្រេច



**ការពិភាក្សា**
និង
**ដេញដោលមតិ**




## I) ការតំណាង:



វាមានសារៈសំខាន់ណាស់ នៅពេលដែលផលប្រយោជន៍នៃសមាជិកទាំងអស់ក្នុងសង្គមមួយ មានអ្នកតំណាងរបស់ខ្លួននៅក្នុងអំឡុងពេលនៃដំណើរការនីតិកម្ម ។ ការតំណាងមានន័យថា **រដ្ឋសភាផ្សារភ្ជាប់រដ្ឋាភិបាល ជាមួយប្រជាពលរដ្ឋ** ។

> មាត្រា៧៧ CC:
>
> តំណាងរាស្ត្រក្នុងរដ្ឋសភា ជាតំណាងប្រជាជាតិខ្មែរទាំងមូល ពុំមែនគ្រាន់តែជាតំណាងប្រជាពលរដ្ឋក្នុងមណ្ឌលរបស់ខ្លួននោះទេ ។

១) ដំបូងបង្អស់ គេត្រូវធានាថា **តំណាងរាស្ត្រ**នៅក្នុងរដ្ឋសភាទាំងអស់ត្រូវបានបោះឆ្នោតជ្រើសរើសឡើងតាម**លក្ខណៈសមាមាត្រ**នៅទូទាំងប្រទេស ។ សម្រាប់បណ្ដាខេត្តទាំងអស់ ត្រូវតែមានអាសនៈនៅក្នុងរដ្ឋសភា ។ ខេត្តដែលមានចំនួនប្រជាពលរដ្ឋច្រើនត្រូវមានអាសនៈ និងឥទ្ធិពលច្រើនជាងខេត្តដែលមានចំនួនប្រជាពលរដ្ឋតិច (មាត្រា៩ នៃច្បាប់ស្ដីពីការបោះឆ្នោតជ្រើសរើសតំណាងរាស្ត្រ LEMNA) ។

> មាត្រា៩ LEMNA:
>
> តំណាងរាស្ត្រត្រូវបានជ្រើសតាំងដោយការបោះឆ្នោតជាទូទៅ ជាសកល ដោយសេរី ត្រឹមត្រូវ និងយុត្តិធម៌ ដោយស្មើភាព ដោយចំពោះ តាមវិធីជ្រើសរើសឆ្នោតជាសំងាត់។ ការបោះឆ្នោត ត្រូវធ្វើតាមប្រព័ន្ធសមាមាត្រតាមខេត្ត-ក្រុង ដោយយកខេត្ត-ក្រុង ជាមណ្ឌលបោះឆ្នោត ។

ឧទាហរណ៍:

គោលការណ៍នៃប្រព័ន្ធសមាមាត្រ មិនគ្រាន់តែអនុវត្តសម្រាប់ការបែងចែកអសនៈក្នុងរដ្ឋសភា សម្រាប់គណបក្សនយោបាយប៉ុណ្ណោះទេ គឺគោលការណ៍នេះក៏ត្រូវបានអនុវត្តសម្រាប់ការងាររបស់រដ្ឋសភាផ្ទាល់ ។

វាអាចជាការរំលោភទៅលើគោលការណ៍នៃភាពសមាមាត្រ នៅពេលដែលប្រធានរដ្ឋសភាមិនបានបញ្ចូលតំណាងរាស្ត្រពីគណបក្សប្រឆាំង ដើម្បីទៅចូលរួមនៅកិច្ចប្រជុំអន្តរជាតិមួយជាមួយសហភាពអន្តរសភា នៅទីក្រុងហ្សឺណែវ ហើយជ្រើសតាំងតែតំណាងរាស្ត្រពីគណបក្សដែលកាន់អំណាចទាំងពីរ ដើម្បីបញ្ជូនទៅចូលរួមកិច្ចប្រជុំនោះ ។

២) វិធីមួយដើម្បីធានានូវ**ការតំណាងឱ្យបានទូលំទូលាយ**នៃសមាជិកសង្គមភាគច្រើន គឺត្រូវឱ្យមាន**សម្លេង ២/៣** សម្រាប់សេចក្តីសម្រេចសំខាន់ៗមួយចំនួន ។ ប្រការនេះធានាថាសេចក្តីសម្រេចនេះមិនមែនគ្រាន់តែតំណាងឱ្យប្រជាពលរដ្ឋលើសពីពាក់កណ្តាលបន្តិចឡើយ ។

ឧទាហរណ៍:

រដ្ឋធម្មនុញ្ញកម្ពុជា មិនអាចត្រូវបានធ្វើវិសោធនកម្មដោយសមាជិកសភាត្រឹម ៥០%+១ នោះឡើយ គឺការងារនេះទាមទារនូវសម្លេងភាគច្រើន ២/៣ (មាត្រា១៥១ II CC)។ សម្លេងភាគច្រើនបែបនេះ ក៏ត្រូវការចាំបាច់សម្រាប់ការតែងតាំង និងរំលាយរដ្ឋាភិបាលផងដែរ (មាត្រា៩0 VII និង ៩៨ I CC)។

៣) វិធីមួយទៀតដើម្បីធានានូវ**ការតំណាងឱ្យបានទូលំទូលាយ** គឺត្រូវបង្កើតនូវ**ស្ថាប័ននីតិកម្ម និងការធ្វើសេចក្តីសម្រេចបន្ថែមទៀត** ដែលមិនគ្រាន់តែមានសមាជិកដែលជ្រើសតាំងដោយប្រជាពលរដ្ឋប៉ុណ្ណោះទេ គឺថែមទាំងមានសមាជិកសង្គមដែលត្រូវបានតែងតាំងទៀតផង ។ សមាជិកទាំងឡាយដែលត្រូវបានតែងតាំងនោះអាចតំណាងឱ្យផ្នែកនានានៃសង្គមដែលមានគំនិត និងផលប្រយោជន៍មួយចំនួនធំ ប៉ុន្តែមិនមានលទ្ធភាពដើម្បីបង្កើតគណបក្សនយោបាយដែលឈរឈ្មោះបោះឆ្នោត ហើយអាចកាន់កាប់អាសនៈនៅរដ្ឋសភាធម្មតានោះទេ ។ គោលការណ៍ដែលតំរូវឱ្យមានអង្គការតាក់តែងច្បាប់បន្ថែម ត្រូវគេហៅថា "ទ្វិសភា" (Bi-cameralism) ដែលមានន័យថា ការបង្កើតស្ថាប័នរដ្ឋសភា**ពីរ** ។

ឧទាហរណ៍:

**ព្រឹទ្ធសភាកម្ពុជា**[៦] គឺជាស្ថាប័នមួយបែបនេះ ដែលត្រូវបានបង្កើតឡើងដើម្បីជាតំណាងឱ្យក្រុមមនុស្ស និងផលប្រយោជន៍ពិសេសមួយចំនួន ដែលមិនផ្អែកលើការបោះឆ្នោតទូទៅ ។ ស្ថាប័ននេះ ក៏មានអំណាចក្នុងការបង្កើតច្បាប់ផងដែរ ហើយដើម្បីឱ្យតួនាទីមួយនៅក្នុងដំណើរការនៃការបង្កើតច្បាប់ (មាត្រា៩៩ I,១១២,១១៣ CC)។ សមាជិកព្រឹទ្ធសភា មានអាយុយ៉ាងតិច៤០ឆ្នាំ ដែលមានន័យថាពួកគេជាតំណាងឱ្យមនុស្សវ័យចាស់ និងមានបទពិសោធន៍ (មាត្រា ៩៩ IV ២ CC) ។ ពួកគេ ត្រូវបានតែងតាំងមួយផ្នែកដោយព្រះមហាក្សត្រ ហើយត្រូវជ្រើសតាំងដោយការបោះឆ្នោត "អសកល" (មាត្រា១០០ CC) ។ នោះមានន័យថា មិនមែនរាល់ប្រជាពលរដ្ឋកម្ពុជាទាំងអស់ អាចបោះឆ្នោតជ្រើសតាំងពួកគេឡើយ គឺមានតែក្រុមមនុស្សពិសេសដែលតំណាងឱ្យផលប្រយោជន៍សង្គមផ្សេងៗ ។ សេចក្តីពិស្តារផ្សេងៗត្រូវតាក់តែងឡើងដោយច្បាប់ (មាត្រា ១០១ CC) ។

[៦] សំរាប់ពត៌មានលំអិត សូមមើលទំព័រទី ២៦ និង ២៧

បញ្ហានៅពេលបច្ចុប្បន្ន គឺថាច្បាប់បែបនេះនៅមិនទាន់មាននៅឡើយ ។ ដូច្នេះ គ្មាននរណាដឹងថា តើក្រុមណាអាចចូលរួមនៅក្នុងការបោះឆ្នោតអសកលនោះឡើយ ។ ក្រុមទាំងអស់នោះអាចជាសមាគមកសិករ សភាពាណិជ្ជកម្ម អង្គការស្ត្រី សមាគមយុវជន ។ល។

**សមាជជាតិ** គឺជាស្ថាប័នមួយបែបទៀត ដែលផ្តល់ដោយរដ្ឋធម្មនុញ្ញកម្ពុជា (មាត្រា ១៤៧ CC)។ វាអាចឱ្យប្រជាពលរដ្ឋទទួលព័ត៌មានដោយផ្ទាល់ និងលើកឡើងនូវសំណួរ និងបញ្ហានានា ដែលជាប្រយោជន៍ជាតិ សម្រាប់រដ្ឋអំណាចដើម្បីដោះស្រាយ ។ វាមានអំណាចក្នុងការផ្តល់អនុសាសន៍ ដែលត្រូវយកមកពិចារណាដោយ រដ្ឋាភិបាល ព្រឹទ្ធសភា និងរដ្ឋសភា។

បញ្ហាជាមួយសមាជជាតិ គឺថាច្បាប់ដែលចាំបាច់ ដើម្បីអនុម័តនូវស្ថាប័ននេះ (មើលមាត្រា ១៤៩ II CC) នៅមិនទាន់បង្កើតនៅឡើយ។

៤) ជាទីបញ្ចប់ អ្នកដែលស្ថិតនៅក្នុងចំណោមមនុស្សភាគតិច ត្រូវការវិធីខ្លះដើម្បីបន្លឺឡើងនូវសេចក្តីប្រាថ្នារបស់ពួកគេ និងដើម្បីបញ្ចេញឥទ្ធិពលទៅលើដំណើរការធ្វើសេចក្តីសម្រេចទូទៅនៃនីតិកម្ម ។ ដូច្នេះ ដំណើរការនីតិកម្មមួយជានិច្ចកាល ត្រូវផ្តល់នូវ**វេទិកាបញ្ចេញមតិសម្រាប់ក្រុមមនុស្សភាគតិច (Platform for the articulation of minority position)** ។

ម្យ៉ាងទៀត វាត្រូវផ្តល់**ឱកាសឱ្យក្រុមប្រឆាំង/ភាគតិច/សង្គមស៊ីវិល ត្រូវបានគេឮ (Chance to be heard)** ផងដែរ។ ប្រសិនបើមនុស្សណាម្នាក់មិនត្រូវបានគេស្តាប់ឮទេ ពួកគេនឹងអាក់អន់ចិត្ត ហើយទីបំផុតគេនឹងប្រើអំពើហិង្សា ដើម្បីឱ្យពួកគេចាប់អារម្មណ៍ចំពោះគោលជំហររបស់ខ្លួន ។ លើសពីនេះ **លទ្ធិប្រជាធិបតេយ្យតែងតែមានន័យថាការស្តាប់សម្តីប្រជាពលរដ្ឋ** និងតម្រូវការ និងក្តីរំពឹងរបស់ពួកគេ ។ ដើម្បីផ្តល់វេទិកាមួយសម្រាប់ក្រុមមនុស្សភាគតិចវាមានសារៈសំខាន់ ជាពិសេសនៅពេលដែលសមាជិកសភាភាគច្រើនធ្វើការអនុម័តពង្រាងច្បាប់ដែលដាក់ជូនដោយរដ្ឋាភិបាលដែលជាប់ឆ្នោតជាទូទៅដោយគ្មានការពិភាក្សា ។ ក្រុមមនុស្សភាគតិច ត្រូវមានឱកាសលើកឡើងនូវក្តីកង្វល់របស់ខ្លួន ហើយរិះគន់គោលជំហរភាគច្រើន និងបញ្ចូលនូវគំនិតខ្លះនៅក្នុងដំណើរការនៃការតាក់តែងច្បាប់ ដែលក្រុមភាគច្រើនអាចធ្វេសប្រហែស ឬធ្វើមិនដឹងមិនឮ ។ សេចក្តីសម្រេចភាគច្រើនអាចទទួលយកបានដោយក្រុមភាគតិច នៅពេលណាដែលយ៉ាងហោចណាស់ គេមានឱកាសបញ្ចេញឥទ្ធិពល និងរិះគន់មតិភាគច្រើន ហើយតាមរយៈការធ្វើដូច្នេះ យ៉ាងហោចណាស់ធ្វើឱ្យមតិភាគច្រើនពន្យល់ហេតុផល រិះគិតឡើងវិញ ឬបំភ្លឺនូវគោលជំហររបស់ខ្លួន ។

ខាងក្រោមនេះជាឧទាហរណ៍ល្អៗមួយចំនួនៈ

- រដ្ឋសភាកម្ពុជា បានធ្វើសវនាការសាធារណៈមួយ ហើយនៅក្នុងពេលនោះ គេបានអញ្ជើញ ក្រុមដែលពាក់ព័ន្ធជំនាញការ និងក្រុមសង្គមស៊ីវិល ដើម្បីផ្តល់នូវគំនិតយោបល់របស់គេចំពោះពង្រាងច្បាប់ ។
- អតីតអភិបាលក្រុងភ្នំពេញ រៀបចំសវនាការសាធារណៈមួយ ដោយអញ្ជើញប្រជាពលរដ្ឋមក ជម្រាបគាត់អំពីសេចក្តីប្រាថ្នា និងសេចក្តីត្រូវការរបស់ពួកគេ លើការអភិវឌ្ឍន៍ជនបទ ។
- អង្គការក្រៅរដ្ឋាភិបាល "អុកហ្វាម" បានរៀបចំដំណើរការពង្រាងច្បាប់ តាមលក្ខណៈចូលរួមពិភាក្សា ជាមួយនាយកដ្ឋានរុក្ខាប្រមាញ់ និងជលផល ។ ការងារនេះរួមមានការចុះសួរ និងស្តាប់សម្តីអ្នកនេសាទដែលរងគ្រោះ សហគមន៍ អ្នកនេសាទ និងគ្រួសារអ្នកនេសាទ ។ លទ្ធផល គឺជាពង្រាងច្បាប់ថ្មីមួយស្តីអំពីការនេសាទ ។

## II) តម្លាភាព:



ដំណើរការបង្កើតច្បាប់តាមបែបលទ្ធិប្រជាធិបតេយ្យណាក៏ដោយ ត្រូវតែមាន**តម្លាភាព** ពីព្រោះអ្នកបោះឆ្នោត និងប្រជាពលរដ្ឋ ក៏ដូចជាសមាជិកសភា និងសហគមន៍សង្គមស៊ីវិលដែរ ត្រូវការនូវព័ត៌មានគ្រប់គ្រាន់ **ដើម្បីស្វែងយល់ និងតាមដាន ដំណើរការតាក់តែងច្បាប់ ហើយមិនត្រឹមតែវាយតំលៃលើគុណភាពច្បាប់ប៉ុណ្ណោះទេ តែវាយតំលៃផងដែរទៅលើសមត្ថភាពរបស់អ្នកតាក់តែងច្បាប់** ដែលឈរឈ្មោះឱ្យគេបោះឆ្នោត ។

មានន័យថា ប្រធានបទខាងក្រោមនេះត្រូវមានភាពច្បាស់លាស់ និងអាចយល់ឃើញដោយសាធារណជន (និង សមាជិកសភាខ្លួនឯង!)

- **តើឯកសារនៃពង្រាងច្បាប់** (និងច្បាប់ជាធរមាន) នោះនិយាយពីអ្វី?
- តើឯកសារនៃពង្រាងច្បាប់នោះ ផ្អែកលើ**ការពិតអ្វីខ្លះ**?
- តើក្រុមដែលពាក់ព័ន្ធទាំងអស់មាន**គោលជំហរ និងសំណើ**យ៉ាងណាខ្លះ អំពីពង្រាងច្បាប់នោះ?
- **តើដំណើរការនៃការបង្កើតច្បាប់** វិវត្តន៍ទៅដូចម្តេច? តើសមាជិកសភាណាមួយ តំណាងឱ្យគោលជំហរណាមួយ?
- តើ**ផលប្រយោជន៍ និងនិន្នាការនយោបាយ**ណាមួយ ដែលមានឥទ្ធិពលចំពោះសមាជិកសភាម្នាក់ៗ?

ដើម្បីធ្វើឱ្យដំណើរការនីតិកម្មមានតម្លាភាពក្នុងអត្ថន័យដែលបានរៀបរាប់ខាងលើ ចាំបាច់ត្រូវមានកត្តា និងរចនាសម្ព័ន្ធ ដូចខាងក្រោម:

១) ត្រូវមាន**ការបោះពុម្ពផ្សាយ (Publication) ឯកសារច្បាប់ និងពង្រាងច្បាប់** ដែលសាធារណជន**អាចរកបានដោយងាយ ជាបន្ទាន់ និងដោយមិនចំណាយប្រាក់** ។

បញ្ហា:

នៅពេលបច្ចុប្បន្ននេះ រចនាសម្ព័ន្ធនៃការបោះពុម្ពផ្សាយឱ្យបានគ្រប់គ្រាន់នូវច្បាប់ ឬពង្រាងច្បាប់ មិនទាន់មាននៅក្នុងប្រទេសកម្ពុជាឡើយ ។ វាមានការពិបាកក្នុងការស្វែងរកឯកសារពេញលេញនៃច្បាប់ ដែលមានស្រាប់ (ប៉ុន្តែ សូមមើលមាត្រា៩៣ II CC) ហើយវាកាន់តែពិបាកក្នុងការស្វែងរកឯកសារពង្រាងច្បាប់[៧] ដែលក្នុងករណីជាច្រើន ត្រូវគេរក្សាទុកដូចជារឿងសម្ងាត់ ដោយក្រសួងដែលផលិតឯកសារនោះ ។ ដូច្នេះ ប្រធានបទមួយក្នុងចំណោមប្រធានបទសំខាន់ៗនៃគម្រោង ពង្រាងសកម្មភាពការងារសំរាប់ការកែទម្រង់ច្បាប់ និងតុលាការ គឺត្រូវបង្កើតប្រព័ន្ធបោះពុម្ពផ្សាយមួយបែបនេះ[៨] ។

---

[៧] ដើម្បីស្វែងរកឯកសារពង្រាងច្បាប់ សូមមើលគេហទំព័ររបស់អង្គការស្តារកម្ពុជា www.forum.org.kh/~star-ldp

[៨] ចំពោះពត៌មានពិស្តារអំពីការផ្សព្វផ្សាយច្បាប់នៅក្នុងសង្គមប្រជាធិបតេយ្យ សូមចុច: (http://usinfo.state.gov/products/pubs/archive/freedom/freedom7.htm)
ចំពោះការបោះពុម្ពផ្សាយច្បាប់ សូមមើលឯកសាររបស់លោក សុខ ស៊ីបញ្ញា ស្តីអំពី "សន្ធិសិទអន្តរជាតិស្តីអំពីការកែទម្រង់ច្បាប់កម្ពុជា" ឆ្នាំ១៩៩៨ ទំព័រ១៩៨-២១០ និងឯកសាររបស់លោក សុខ ស៊ីបញ្ញា ស្តីអំពី "យុទ្ធសាស្ត្រដើម្បីកែទម្រង់ច្បាប់ និងតុលាការ សម្រាប់ប្រទេសកម្ពុជា" ឆ្នាំ២០០២ ទំព័រ៣៣-៤០

**២) ត្រូវបើកចំហឱ្យសាធារណជនចូលរួមការពិភាក្សាដេញដោលមតិរបស់រដ្ឋសភា** (និងអង្គការនីតិកម្មណាមួយ ដូចជាក្រុមប្រឹក្សាឃុំ សង្កាត់) ព្រមទាំងអនុញ្ញាតឱ្យសាធារណជន**ទៅសួរសុខទុក្ខដំណាងរាស្ត្រដែលខ្លួនបោះឆ្នោតឱ្យ ។**

បញ្ហា:

- ការបើកចំហដល់សាធារណជនក្នុងការចូលស្តាប់កិច្ចប្រជុំរបស់រដ្ឋសភា និងព្រឹទ្ធសភា ត្រូវបានផ្តល់ឱ្យជាមូលដ្ឋាន ដោយមាត្រា៨៨ I និងមាត្រា១១១ I CC ។ ប៉ុន្តែ បញ្ញត្តិទាំងពីរនេះក៏រួមបញ្ចូលនូវលទ្ធភាពដែលថាកិច្ចប្រជុំទាំងនោះធ្វើឡើងដោយមិនអនុញ្ញាតឱ្យសាធារណជនចូលរួមផងដែរ ដោយគ្រាន់តែមានសំណើយ៉ាងសាមញ្ញពីសមាជិក១/១០ ឬដោយព្រះមហាក្សត្រ ឬដោយនាយករដ្ឋមន្ត្រី ។ បញ្ញត្តិនេះ មិនបានចែងថាគេត្រូវតែផ្តល់ហេតុផលណាមួយសម្រាប់សំណើមួយបែបនេះឡើយ ។ គោលការណ៍ទី៦៤ ផ្នែកទី២ នៃបទបញ្ជាផ្ទៃក្នុងរបស់រដ្ឋសភា ចែងថា "ជាគោលការណ៍" ប្រធានសភាអាចអនុញ្ញាតឱ្យសាធារណជនចេញចូលសាលប្រជុំបាន (ផ្ទុយពីមាត្រា៨៨ I CC!) ។ ដូច្នេះ វាស្រេចតែទៅលើមនុស្សទាំងអស់នោះក្នុងការហាមប្រាមសាធារណជនដោយគ្មានផ្តល់ហេតុផលណាមួយឡើយ ប្រសិនបើគេចង់ធ្វើដូច្នេះ ។

វាមិនស្របទៅនឹងគំនិតជាមូលដ្ឋាន នៃការបង្កើតច្បាប់តាមបែបលទ្ធិប្រជាធិបតេយ្យ ។ តំណាងរាស្ត្រដែលជាប់ឆ្នោត ក៏ដូចជារដ្ឋាភិបាល មិនគួរមានការសម្ងាត់អ្វីលាក់បាំងពីសាធារណជនឡើយ ។ ប្រសិនបើគេរារាំងមិនឱ្យសាធារណជនដឹងពត៌មានផ្សេងៗ ពួកគេបង្កនូវការខូចខាតដ៏ធ្ងន់ធ្ងរ ចំពោះភាពស្របច្បាប់នៃដំណើរការបង្កើតច្បាប់ ។ តើប្រជាពលរដ្ឋកម្ពុជាអាចទុកចិត្តដូចម្តេច ថាតើច្បាប់ដែលគេបង្កើតនោះ ត្រូវបានធ្វើឡើងតាមរបៀបមួយដែលយុត្តិធម៌ និងសមហេតុផល នៅពេលដែលខ្លួនមិនដឹងអំពីខ្លឹមសារនៃការពិភាក្សាដេញដោលមតិនោះ? វាអាចមានហេតុផលខ្លះដែលគេត្រូវលាក់បាំងពីសាធារណជន ដូចជា នៅពេលដែលគេពិភាក្សាអំពីការសម្ងាត់យោធា ប៉ុន្តែការនេះគួរតែបញ្ជាក់ឱ្យច្បាស់ និងតាមផ្លូវច្បាប់ថា ការពិភាក្សាដេញដោលមតិមិនអាចធ្វើជាសាធារណៈបានឡើយ ។

- ការដែលមិនស្របទៅនឹងគោលការណ៍ប្រជាធិបតេយ្យជាមូលដ្ឋាននៃសិទ្ធិរបស់សាធារណជន ក្នុងការចូលរួមកិច្ចប្រជុំនីតិកម្ម ក៏ជាសេចក្តីសម្រេចមួយរបស់សាលាក្រុងភ្នំពេញ ដែលមិនអនុញ្ញាតឱ្យអ្នកកាសែត និងសាធារណជនចូលរួមអង្គប្រជុំរបស់ខ្លួននោះ ។ មាត្រា៤ I នៃច្បាប់សារពត៌មាន និងមាត្រា៤១ I ១ CC (ដែលចែងថាសេរីភាពក្នុងការបញ្ចេញមតិ រួមបញ្ចូលទាំងសិទ្ធិក្នុងការទទួលពត៌មានដោយ សេរីនោះ) មិនបានបញ្ជាក់ថា សេចក្តីសម្រេចបែបនេះ វាត្រឹមត្រូវឡើយ ។
- វាក៏ហាក់ដូចជាមិនស្របទៅនឹងគំនិតនៃដំណើរការបង្កើតច្បាប់ ដែលមានតម្លាភាពឡើយ ប្រសិនបើ អគ្គលេខាធិការរបស់រដ្ឋសភាអះអាងថា រាល់អ្នកកាសែតទាំងអស់ដែលចេញចូលរដ្ឋសភាត្រូវតែជូនដំណឹងដល់រដ្ឋបាលរបស់រដ្ឋសភា ថាតើសមាជិកសភាណាមួយដែលខ្លួនចង់ជួបនោះ ។ ការតម្រូវឱ្យជូនពត៌មានបែបនេះ បង្កើតនូវយន្តការមួយសំរាប់គ្រប់គ្រង ដែលធ្វើឱ្យខូចខាតដល់គោលការណ៍នៃការផ្លាស់ប្តូរដោយសេរី និងមិនមានការគ្រប់គ្រងនូវគំនិតយោបល់ រវាងសមាជិកសភា និងពលរដ្ឋ ។ វាគ្មានហេតុផលអ្វីដែលថា អគ្គលេខាធិការរដ្ឋសភាចាំបាច់ត្រូវតែដឹងរឿងនេះឡើយ ។

**៣) ប្រវត្តិទាក់ទងនឹងសេដ្ឋកិច្ច និងការចូលរួមអង្គការណាមួយ** (សមាជិកសមាគម សមាជិកក្រុមហ៊ុន ។ល។) **របស់សមាជិកសភាម្នាក់ៗ** គួរតែត្រូវតែ**បោះពុម្ពផ្សាយ**នៅក្នុងសៀវភៅសមាជិកសភា (ដែលមានដូចជានៅប្រទេសអាល្លឺម៉ង់) ព្រមទាំង**របៀបវារៈនៃកិច្ចប្រជុំនីតិកម្ម** (មាត្រា៨៣ III CC គ្រាន់តែបោះពុម្ពផ្សាយ

របៀបវារៈនៃអង្គប្រជុំវិសាមញ្ញរបស់រដ្ឋសភាតែប៉ុណ្ណោះ ។ ប៉ុន្តែ គេគួរតែបោះពុម្ពផ្សាយ វាដោយឡែកសម្រាប់អង្គប្រជុំសាមញ្ញផងដែរ) ។ ព្រោះហេតុដូច្នេះ សាធារណជន អាចវាយតម្លៃសកម្មភាពរបស់តំណាងរាស្ត្ររបស់ខ្លួន និងអាចតាមដានដំណើរការបង្កើតច្បាប់កាន់តែប្រសើរ ។

## III) ការពិភាក្សា និងជជែកដេញដោលមតិ: (Discussion and Debate)




អង្គនីតិបញ្ញត្តិ ជាញឹកញាប់ គឺជា**វេទិកា**ដែលប្រសើរ និងស្របច្បាប់ **សម្រាប់ជជែកដេញដោលរកមតិផ្សេងៗគ្នា** ។ រាល់សង្គមទាំងអស់ សុទ្ធតែមានទស្សនៈផ្សេងគ្នាអំពីទិសដៅនយោបាយ និងមាតិកាដែលត្រូវដាក់ក្នុងរបៀបវារៈជាតិ និងមានក្រុមផ្សេងៗដែលទទួលបាននូវការយកចិត្តទុកដាក់ពិសេស ។ ការផ្តល់ឱកាស និង**បរិយាកាសដែលល្អបំផុត សម្រាប់ការជជែកដេញដោលមតិពិតប្រាកដ** គឺជាមុខងារសំខាន់មួយរបស់អង្គនីតិបញ្ញត្តិ ។

មុខងារចំបងមួយ គឺត្រូវផ្តល់ការិយាល័យមួយសម្រាប់គណបក្សប្រឆាំងស្របច្បាប់ ។ **ការរិះគន់ក្នុងន័យស្ថាបនា** ចំពោះរដ្ឋាភិបាល ឬពង្រាងច្បាប់មួយ គួរតែត្រូវបានគេស្វាគមន៍ ហើយមិនគួរគិតថា គឺជាឧបសគ្គនោះឡើយ ពីព្រោះគឺជា**ឱកាសក្នុងការស្វែងរកដំណោះស្រាយដែលប្រសើរបំផុតសម្រាប់សង្គម ។**

ពាក្យថា "រដ្ឋសភា (Parliament)" ចេញមកពីពាក្យបារាំងថា "Parler" ដែលមានន័យថា "និយាយ" ។ គំនិតប្រជាធិបតេយ្យ ពឹងផ្អែកទៅលើ**ការពិភាក្សារួមគ្នា** ដោយរស់រវើក និង**ដោយចំហ** អំពីបញ្ហាទាំងអស់ជា**មធ្យោបាយដែលប្រសើរបំផុត និងអហិង្សា សម្រាប់ដោះស្រាយទំនាស់នានា** ដែលកើតមាននៅក្នុងសង្គមនីមួយៗ ។

វប្បធម៌នៃការដេញដោលមតិបែបនេះ មាននៅក្នុងរដ្ឋធម្មនុញ្ញកម្ពុជាដែលផ្តល់ដល់សមាជិកសភា នូវសិទ្ធិដូចខាងក្រោម:

- **អភ័យឯកសិទ្ធិ:** មាត្រា៨០ II និងមាត្រា១០៤ II ១ CC ផ្តល់ការការពារដល់សមាជិកសភាមិនឱ្យទទួលការកាត់ទោសដោយសារតែការបញ្ចេញមតិ ក្នុងអំឡុងពេលបំពេញមុខងាររបស់ខ្លួន ។
- **សិទ្ធិក្នុងការដេញដោលសួរសមាជិករដ្ឋាភិបាល និងអាជ្ញាធរ** ក្នុងអំឡុងពេលប្រជុំសភា (មើលមាត្រា៨៩, ៩៦ I, ៩៧ CC ព្រមទាំងគោលការណ៍ទី ៣២, ៣៣ នៃបទបញ្ជាផ្ទៃក្នុងរបស់រដ្ឋសភា)
- **សិទ្ធិក្នុងការនិយាយស្តី** (មើលគោលការណ៍ទី ៥៤-៦១ នៃបទបញ្ជាផ្ទៃក្នុងរបស់រដ្ឋសភា)

រដ្ឋធម្មនុញ្ញបានចែងយ៉ាងច្បាស់ថា វាត្រូវតែមានពេលសម្រាប់សំណួរចម្លើយ ដែលមានន័យថាជាការពិភាក្សា។

> មាត្រា៩៦ VI CC:
>
> រដ្ឋសភាកំណត់ទុកពេលមួយថ្ងៃក្នុងមួយសប្តាហ៍ សម្រាប់ការឆ្លើយសំណួរ ។ ទោះបីយ៉ាងណាក៏ដោយ សម័យប្រជុំសំរាប់ឆ្លើយសំណួរខាងលើ មិនអាចបើកលទ្ធភាពឱ្យមានការបោះឆ្នោតប្រភេទណាមួយបានឡើយ ។

ដើម្បីផ្តល់ឱកាសក្នុងការអនុវត្តសិទ្ធិទាំងនេះ ជាពិសេសប្រធានសភាត្រូវតែយកចិត្តទុកដាក់ចំពោះសមាជិកគណបក្សប្រឆាំងឱ្យទទួលបានរយៈពេលត្រឹមត្រូវ និងឱកាសនិយាយ ដោយគ្មានការរំខានណាមួយឡើយ ។

# នីតិកម្ម

### ការធ្វើសេចក្ដីសំរេច បែបលទ្ធិប្រជាធិបតេយ្យ

នៅក្នុងចំណោម សមាជិកក្រុមទាំងអស់

- សមភាព
- វិធានដែលបង្កើត ដោយខ្លួនឯង
- ពហុបក្ស

លទ្ធិប្រជាធិបតេយ្យ= វិធានរបស់ប្រជាពលរដ្ឋ

### ការអនុវត្តន៍អំណាច របស់ប្រជាពលរដ្ឋ

អំណាចប្រជាពលរដ្ឋ ត្រូវបែងចែក ជា៣ផ្នែក មាត្រា៥១ III, IV CC:

- នីតិបញ្ញត្តិ
- តុលាការ
- នីតិប្រតិបត្តិ

សភាជាតិ:

- ធ្វើវិធានបទដ្ឋាន និង
- ត្រួតពិនិត្យការអនុវត្តន៍ វិធានបទដ្ឋាន/សេចក្ដី សំរេច

បញ្ហា: តើសភាមាន អំណាចគ្រប់គ្រាន់ក្នុងការ ពិនិត្យ នីតិប្រតិបត្តិទេ?

### ធាតុសំខាន់ៗនៃការធ្វើសេចក្ដីសំរេច

**ការតំណាង:**

- ដោយសមាមាត្រ: អាសនៈនៅក្នុងសភាជាតិ សិទ្ធិរបស់សមាជិកសភា
- ភាគច្រើន ២/៣: ជាពិសេសការតំណាងទូទៅមួយក្នុងការធ្វើសេចក្ដីសំរេចសំខាន់ៗ
- ទ្វិសភា: ព្រឹទ្ធសភា សភាជាតិ (និងសមាជជាតិដែលស្ថាប័នទី៣ មាននៅកម្ពុជា)
- ស្ដាប់ប្រជាពលរដ្ឋ: សវនាការជាសាធារណៈ ការចូលរួមការពង្រាងច្បាប់

**តម្លាភាព:**

នៃ

- អត្ថបទច្បាប់/ពង្រាងច្បាប់
- គោលជំហរផ្សេងគ្នា
- សមាជិកសភា
- ដំណើរការតាក់តែងច្បាប់

តាមរយៈ

- ការផ្សព្វផ្សាយ
- ការបើកចំហរឱ្យចូលរួមពិភាក្សា
- ការបើកចំហរឱ្យសួរសមាជិកសភា
- សៀវភៅនិយាយអំពីសមាជិកសភា

**ការពិភាក្សា**

អភ័យឯកសិទ្ធិ

សិទ្ធិសួរដេញដោល

សិទ្ធិក្នុងការនិយាយ

## ? សំនួរសិក្សាទី ១

ចូរមើលរដ្ឋធម្មនុញ្ញកម្ពុជា និងរៀបរាប់អំពីមុខងាររបស់សភា (សភាជាតិ)!

## ? សំនួរសិក្សាទី ២

តើធាតុចំបងណាមួយនៃការធ្វើសេចក្ដីសំរេចបែបប្រជាធិបតេយ្យ អាចត្រូវបានរកឃើញនៅក្នុងអត្ថបទសង្ខេបដែលដកស្រង់ចេញពីសារព័ត៌មាន The Cambodian Daily ចុះថ្ងៃទី ០៣ ខែមេសា ឆ្នាំ ២០០៣?

ក្រសួងយុត្តិធម៌ បានពិភាក្សាជាមួយអង្គការក្រៅរដ្ឋាភិបាល អំពីការពន្យាពេលលើពង្រាងច្បាប់ស្ដីពីលក្ខន្តិកៈរបស់ចៅក្រម និងព្រះរាជអាជ្ញា ។ ច្បាប់ដែលបានពង្រាងតាំងពីឆ្នាំ ១៩៩៤ ចែងអំពីវិធានស្ដីអំពីការបណ្ដុះបណ្ដាល ភាពមិនលំអៀង ប្រាក់បៀវត្ស និងទោសផ្នែកវិន័យ របស់ចៅក្រម ។ លោក កឹម សុខា នាយកមជ្ឈមណ្ឌលកម្ពុជាដើម្បីសិទ្ធិមនុស្ស បាននិយាយថា វានៅតែត្រូវបញ្ជាក់ថាតើពង្រាងច្បាប់នោះ នឹងត្រូវបានអនុវត្តដែរឬទេ ចំណែកឯ លោក គី តិច ប្រធានគណៈមេធាវីកម្ពុជា បានធ្វើការសរសើរដល់ពង្រាងច្បាប់នោះ ប៉ុន្តែលោកបាននិយាយថា វាមានលក្ខណៈមិនច្បាស់អំពីបទល្មើសដែលនាំឱ្យមានការដាក់ទោសផ្នែកវិន័យ ។